ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៧៨ ពណ.អវង.ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារឃ្លាំមើលស្ថានភាព និងសន្ទស្សន៍ថ្លៃមុខទំនិញចាំបាច់ ដែលបម្រើឲ្យជីវភាពប្រចាំថ្ងៃ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងប្រកាសលេខ ១៥២ ពណ.អវង.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារឃ្លាំមើលស្ថានភាព និងសន្ទស្សន៍ថ្លៃមុខទំនិញចាំបាច់ដែលបម្រើឲ្យជីវភាពប្រចាំថ្ងៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារ ឃ្លាំមើលស្ថានភាព និងសន្ទស្សន៍ថ្លៃមុខទំនិញ ចាំបាច់ ដែលបម្រើឲ្យជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| **១- ឯកឧត្តម ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| **២- ឯកឧត្តម សុខ សុភ័ក្រ** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| **៣- ឯកឧត្តម រ៉ា វុតសាន** | ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម | អនុប្រធាន |

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ៖ (៨៥៥) -២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

| | | |
|---|---|---|
| ៤- ឯកឧត្តម ប៉ែន សុវិជាតិ | អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |
| ៥- ឯកឧត្តម ស៊ាង ថៃ | អគ្គនាយកជំរុញពាណិជ្ជកម្ម | សមាជិក |
| ៦- ឯកឧត្តម ស៊ឹម សុខខេង | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ | សមាជិក |
| ៧-លោក វង្ស សារ៉ាវុធ | អគ្គនាយករងពាណិជ្ជកម្មអន្តរជាតិ | សមាជិក |
| ៨- លោក ឡាយ សុខសៅគន្ធា | អគ្គនាយករងពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |
| ៩- លោក តឹម មាសសុខសីហា | អគ្គនាយករងកាំកុងត្រូល | សមាជិក |
| ១០-លោក ចាន់ សុខទី | អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ | សមាជិក |
| ១១-លោក ហូ ស៊ីវយ៉ុង | ប្រធាននាយកដ្ឋាននាំចេញ-នាំចូល | សមាជិក |
| ១២-លោក ឈាវ ផា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ | សមាជិក |
| ១៣-លោក អ៊ួង សុខន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | សមាជិក |
| ១៤-លោក គិត ភារ៉ា | ប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម | សមាជិក |
| ១៥- លោក ឡុង កែមវិចិត្រ | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦- ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- សិក្សា និងចងក្រងឯកសារទាក់ទងនឹងស្ថានភាពផលិតកម្ម ថ្លៃដើម (Cost Structure) សមត្ថភាពផ្គត់ផ្គង់ ការប្រើប្រាស់ និងសន្ទស្សន៍ថ្លៃ នៃមុខទំនិញអាទិភាពដូចជា៖ ស្រូវ-អង្ករ ត្រី សាច់មាន់ សាច់ជ្រូក ប្រេងសាំងធម្មតា និងម៉ាស៊ូត ដំឡូងមី ពោតចំណីសត្វ និងម្រេច
- ធ្វើបច្ចុប្បន្នភាពបញ្ជីមុខទំនិញអាទិភាព និងអាចពង្រីកបន្ថែមមុខទំនិញ តាមការពាក់ព័ន្ធ និងចាំបាច់
- តាមដាន ពិនិត្យ ឃ្លាំមើល ស្ថានភាពប្រែប្រួលនៃផលិតកម្ម ស្ថានភាពទំនិញចរាចរលើ ទីផ្សារ និងដាក់ចេញនូវវិធានការចាំបាច់ដើម្បីទ្រទ្រង់ផលិតកម្ម និងថ្លៃទំនិញលើទីផ្សារ
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានានាទាក់ទងនឹងផលិតកម្ម ថ្លៃទំនិញ ផលប៉ះពាល់ពីការនាំចូលមុខទំនិញដូចគ្នា មកលើទំនិញក្នុងស្រុក រកទីផ្សារក្នុងស្រុក និងក្រៅប្រទេស
- រៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងរាជរដ្ឋាភិបាល ជាប្រចាំ។

**ប្រការ ៣.-**

ក្រុមការងារនេះអាចប្រើប្រាស់ថវិកាជាតិ ដែលជាកញ្ចប់ថវិកា របស់ក្រសួងពាណិជ្ជកម្ម ឬថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍នានា និងថវិកាពីប្រភពផ្សេងៗទៀត ដែលច្បាប់អនុញ្ញាត។

**ប្រការ ៤.-**

ក្រុមការងារនេះមានលេខាធិការដ្ឋានដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - លោក អ៊ួង សុខន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | ប្រធាន |
| - លោក គិត ភារ៉ា | ប្រធាននាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| - លោក សួន វិជ្ជា | ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | អនុប្រធាន |
| - លោក ផុល ណារ៉ា | ប្រធាននាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក | អនុប្រធាន |

- **លោក ជា ប៊ុនធៀង** អនុប្រធាននាយកដ្ឋានគោលនយោបាយ សមាជិក
- **លោក លឹម អមរិន្ទ** អនុប្រធានការិយាល័យ សមាជិក

លេខាធិការដ្ឋាន អាចស្នើសុំមន្ត្រីពីនាយកដ្ឋានពាក់ព័ន្ធមកជួយការងារតាមការចាំបាច់។

**ប្រការ ៥.-**

អនុប្រធាន និងសមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំកិច្ចប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៦.-**

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងសាមីខ្លួនត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**ចម្លងជូន៖**

- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ**សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១ ប្រការ៤ និងប្រការ៧
- ឯកសារ-កាលប្បវត្តិ